# ច្បាប់ ESEA ដែលអាចលើកលែង

# ការចាត់តាំងសាលាដែលទទួលការឧបត្ថម្ភដោយច្បាប់ Title I

| | យកចិត្តទុកដាក់ | សំខាន់ជាងគេ | រង្វាន់ (ជោគជ័យកម្រិតខ្ពស់) | រង្វាន់ (ការរីកចម្រើនកម្រិតខ្ពស់) |
|---|---|---|---|---|
| លក្ខណៈវិនិច្ឆ័យសម្រាប់ការចាត់តាំង | • ចំនួន១០ភាគរយ នៃកម្រិតទាបបំផុត នៃសាលាដែលឧបត្ថម្ភដោយច្បាប់ Title I ៖ (យោងទៅលើ គម្លាតនៃជោគជ័យក្នុងការសិក្សាខ្ពស់បំផុត សម្រាប់ផែនការនៃការស្ទង់មើលប្រចាំឆ្នាំ ចំពោះសិស្សដែលមានប្រវត្តិរៀនខ្សោយ)។ គម្លាតនៃជោគជ័យក្នុងការសិក្សាសរុបគឺសម្រាប់ការប្រឡង PSSA ផ្នែក គណិតវិទ្យា/ការអាន និង/ឬ ការប្រឡង Keystone ផ្នែក ពិជគណិត ១/អក្សរសាស្ត្រ រួមបញ្ចូលគ្នា។<br>**ឬ**<br>• សាលាដែលឧបត្ថម្ភដោយច្បាប់ Title I ដែលមានសិស្សបញ្ចប់ការសិក្សាតិចជាង ៦០ភាគរយ។<br>**ឬ**<br>• បេក្ខជនចូលរួមប្រឡងមានចំនួនតិចជាង៩៥ភាគរយ **ហើយ** មិនមែនជាសាលាដែលសំខាន់ជាងគេ។ | • ចំនួន៥ភាគរយ នៃកម្រិតទាបបំផុត នៃសាលាដែលឧបត្ថម្ភដោយច្បាប់ Title I ៖ (យោងទៅលើកម្រិតនៃចំណេះដឹងសរុបផ្នែក គណិតវិទ្យា និង ការអាន នៃការប្រឡង PSSA និង/ឬ ការប្រឡង Keystone ផ្នែក ពិជគណិត ១/អក្សរសាស្ត្រ។<br>**ឬ**<br>• សាលាដែលឧបត្ថម្ភដោយច្បាប់ Title I ទទួលថវិកាដើម្បីកែលម្អសាលា (SIG)។ | • ចំនួន៥ភាគរយ នៃកម្រិតខ្ពស់បំផុត នៃសាលាដែលឧបត្ថម្ភដោយច្បាប់ Title I៖ (យោងទៅលើកម្រិតនៃចំណេះដឹងសរុបផ្នែក គណិតវិទ្យា និង ការអាន នៃការប្រឡង PSSA និង/ឬ ការប្រឡង Keystone ផ្នែក ពិជគណិត ១/អក្សរសាស្ត្រ។<br>**និង**<br>• ធ្វើបានតាម ផែនការនៃការស្ទង់ មើលប្រចាំឆ្នាំ (AMOs) ទាំងបួន។ (កំណត់សម្គាល់៖ សម្រាប់ទិន្នន័យនៃឆ្នាំ ២០១២-១៣ គេមិនស្ទង់មើល ការលប់បំបាត់គម្លាតនៃជោគជ័យក្នុងការសិក្សាទេ ដោយសារនេះជាឆ្នាំដំបូង។)<br>**និង**<br>• មិនមែនជាសាលាដែលសំខាន់ជាងគេ ឬ សាលាដែលគេយកចិត្តទុកដាក់។ | • សម្រាប់ឆ្នាំសិក្សា ២០១១-១២ និង ២០១២-១៣៖ ចំនួន ៥ភាគរយ នៃកម្រិតខ្ពស់បំផុត នៃសាលាដែលឧបត្ថម្ភដោយច្បាប់ Title I ដោយយោងទៅលើពិន្ទុសរុបនៃការរីកចម្រើនរបស់ PVAAS ផ្នែកការអាន និង គណិតវិទ្យា នៃការប្រឡង PSSA និង/ឬ ការប្រឡង Keystone ផ្នែក ពិជគណិត ១ /អក្សរសាស្ត្រ សម្រាប់សិស្សទាំងអស់។<br>**ឬ**<br>• សម្រាប់ឆ្នាំសិក្សា ២០១៣-១៤ និង ហួសពីនេះ៖ ចំនួន ៥ភាគរយ នៃកម្រិតខ្ពស់បំផុត នៃសាលាដែលឧបត្ថម្ភដោយច្បាប់ Title I ដោយយោងទៅលើ ការរីកចម្រើនសរុប ក្នុងការបំបាត់គម្លាតនៃជោគជ័យក្នុងការសិក្សា ផ្នែកការអាន និង គណិតវិទ្យា នៃការប្រឡង PSSA និង/ឬ ការប្រឡង Keystone ផ្នែក ពិជគណិត ១/អក្សរសាស្ត្រ សម្រាប់សិស្សទាំងអស់ និងក្រុម « សិស្សដែលមានប្រវត្តិរៀនខ្សោយ»។<br>**និង**<br>ធ្វើបានតាម ផែនការនៃការស្ទង់មើលប្រចាំឆ្នាំ ទាំងបួន។ (កំណត់សម្គាល់៖ សម្រាប់ទិន្នន័យនៃឆ្នាំ២០១២-១៣ គេមិនស្ទង់មើល ការលប់បំបាត់គម្លាតនៃជោគជ័យក្នុងការសិក្សាទេ ដោយសារនេះជាឆ្នាំដំបូង។)<br>**និង**<br>• មិនមែនជារង្វាន់៖ សាលាដែលមានជោគជ័យកម្រិតខ្ពស់ សាលាដែលគេយកចិត្តទុកដាក់ សាលាដែលសំខាន់ជាងគេ។ |

| | យកចិត្តទុកដាក់ | សំខាន់ជាងគេ | រង្វាន់ (ជោគជ័យកម្រិតខ្ពស់) | រង្វាន់ (ការរីកចម្រើនកម្រិតខ្ពស់) |
|---|---|---|---|---|
| **តម្រូវការ** | • សាលាដែលគេ**យកចិត្តទុកដាក់**ទាំងអស់ ត្រូវអនុវត្តយ៉ាងហោចណាស់ ការធ្វើអន្តរាគមន៍មួយដែលទាក់ទងផ្ទាល់នឹង ផែនការនៃការស្ទង់មើលប្រចាំឆ្នាំ ដែលធ្វើមិនបានតាមតម្រូវការ។<br>• សាលាដែលគេបានចាត់តាំងឲ្យទៅជាសាលាដែលគេយកចិត្តទុកដាក់ ដោយយោងទៅលើទិន្នន័យនៃឆ្នាំ២០១២-១៣ នឹងត្រូវគេតម្រូវឲ្យអនុវត្តផែនការដ៏ទូលំទូលាយសម្រាប់ការកែលម្អ។<br>• តម្រូវឲ្យមានការពិភាក្សាជាមួយ ក្រុម អន្តរការី និង បណ្ដាញផ្ដល់ជំនួយផ្នែក ហ្វឹកហ្វឺន និង បច្ចេកទេស នៃរដ្ឋផិនស៊ីលវេនញ៉ា - Pennsylvania Training and Technical Assistance Network (PaTTAN) (ដោយស្របទៅតាមសេចក្ដីត្រូវការ)<br>• ចាប់ផ្ដើមនៅឆ្នាំ២០១៤-១៥ គេតម្រូវឲ្យក្រសួងអប់រំ ទុកប្រាក់ឧបត្ថម្ភដោយច្បាប់ Title I ចំនួន២០ភាគរយ សម្រាប់ ការធ្វើអន្តរាគមន៍ដែលសំខាន់។ | • គេតម្រូវឲ្យ សាលាដែលសំខាន់ជាងគេទាំងអស់ អនុវត្តការធ្វើអន្តរាគមន៍ដែលទាក់ទងនឹងគោលការទាំងប្រាំពីរនៃការបង្វែរទិសដៅសាលា។ លក្ខណៈ និង កម្រិត នៃគោលការ ដែលគេអនុវត្ត អាចមានលក្ខណៈខុសៗគ្នា ទៅតាម សេចក្ដីត្រូវការ/សិស្ស នៅសាលានីមួយៗ។<br>• នៅពេលដែលគេជូនដំណឹង គេតម្រូវឲ្យសាលាពិនិត្យផែនការកែលម្អរបស់សាលា ដែលមានស្រាប់។<br>• ចាប់ផ្ដើមនៅឆ្នាំ២០១៤-១៥ គេតម្រូវឲ្យក្រសួងអប់រំ ទុកប្រាក់ឧបត្ថម្ភដោយច្បាប់ Title I ចំនួន២០ភាគរយ សម្រាប់ ការធ្វើអន្តរាគមន៍ដែលសំខាន់។<br>• ការបង្កើតផែនការកែលម្អរបស់សាលា យោងទៅតាមការអនុវត្តន៍ការធ្វើអន្តរាគមន៍ដែលសំខាន់ៗទាំងអស់ ដែលគេបានរកឃើញ សម្រាប់គោលការបង្វែរទិសដៅ ដោយប្រើវិធីសាស្ត្រនៃផែនការដ៏ទូលំទូលាយ។ | | |